**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៣៩០ សហវ. [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការកែសម្រួលពន្ធគយ និងការដាក់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ លើទំនិញនាំចូលមួយចំនួន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៦៥ សហវ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឲ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧
- បានឃើញចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៨ លើលិខិតលេខ ១៩១៩ សហវ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការលើកទឹកចិត្តដល់ផលិតករក្នុងស្រុក។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh. CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**<u>សម្រេច</u>**

**ប្រការ ១.-**

ត្រូវបានកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួនដែលមានចែងក្នុងតារាងពន្ធគយកម្ពុជាជាធរមានដូចខាងក្រោមនេះ ៖

១. កែសម្រួលអត្រាពន្ធគយពីអត្រាដែលមានស្រាប់ មកសូន្យភាគរយ (០%) សម្រាប់បណ្តាមុខទំនិញនៃទីតាំងរងលេខ ០៦០១.១០.០០ ០៦០១.២០.១០
០៦០១.២០.២០ ០៦០១.២០.៩០ ០៦០២.១០.១០ ០៦០២.១០.២០ ០៦០២.១០.៩០
០៦០២.២០.០០ ០៦០២.៣០.០០ ០៦០២.៤០.០០ ០៦០២.៩០.៣០ ០៦០២.៩០.៤០
១០០៦.១០.០០ ១០០៧.០០.០០ ១០០៨.១០.០០ ១០០៨.២០.០០ ១០០៨.៩០.០០
១២០៤.០០.០០ ១២០៥.១០.០០ ១២០៩.៩៩.៩០ ១២១៤.១០.០០ ១២១៤.៩០.០០
២៣០១.១០.០០ ២៣០១.២០.០០ ២៣០២.១០.០០ ២៣០២.៣០.០០ ២៣០២.៤០.១០
២៣០២.៤០.៩០ ២៣០២.៥០.០០ ២៣០៣.១០.១០ ២៣០៣.១០.៩០ ២៣០៣.២០.០០
២៣០៣.៣០.០០ ២៣០៤.០០.០០ ២៣០៥.០០.០០ ២៣០៦.១០.០០ ២៣០៦.២០.០០
២៣០៦.៣០.០០ ២៣០៦.៤១.០០ ២៣០៦.៤៩.០០ ២៣០៦.៥០.០០ ២៣០៦.៦០.០០
២៣០៦.៩០.២០ ២៣០៦.៩០.៩០ ២៣០៧.០០.០០ ២៣០៨.០០.០០ ២៣០៩.១០.១០
២៣០៩.១០.៩០ ២៣០៩.៩០.១១ ២៣០៩.៩០.១២ ២៣០៩.៩០.១៣ ២៣០៩.៩០.១៩
២៣០៩.៩០.២០ ២៣០៩.៩០.៣០ ២៣០៩.៩០.៩០ ៣៨០៨.៥០.១៣ ៣៨០៨.៥០.១៩
៣៨០៨.៥០.២០ ៣៨០៨.៥០.៩១ ៣៨០៨.៥០.៩៩ ៣៨០៨.៩១.១០ ៣៨០៨.៩១.២០
៣៨០៨.៩១.៣០ ៣៨០៨.៩១.៩០ ៣៨០៨.៩២.០០ ៣៨០៨.៩៣.០០ ៣៨០៨.៩៤.០០
៣៨០៨.៩៩.១០ ៣៨០៨.៩៩.៩០ ៧៤០១.០០.០០ ៧៤០២.០០.០០ ៧៤០៣.១១.០០
៧៤០៣.១២.០០ ៧៤០៣.១៣.០០ ៧៤០៣.១៩.០០ ៧៤០៣.២១.០០ ៧៤០៣.២២.០០
៧៤០៣.២៩.០០ ៧៤០៥.០០.០០ ៧៤០៦.១០.០០ ៧៤០៦.២០.០០ ៧៤០៧.១០.៣០
៧៤០៧.១០.៩០ ៧៤០៧.២១.០០ ៧៤០៧.២៩.០០ ៧៤០៩.១១.០០ ៧៤០៩.១៩.០០
៧៤០៩.២១.០០ ៧៤០៩.២៩.០០ ៧៤០៩.៣១.០០ ៧៤០៩.៣៩.០០ ៧៤០៩.៤០.០០
៧៤០៩.៩០.០០ ៧៥០១.១០.០០ ៧៥០១.២០.០០ ៧៥០២.១០.០០ ៧៥០២.២០.០០
៧៥០៤.០០.០០ ៧៥០៦.១០.០០ ៧៥០៦.២០.០០ ៧៦០៣.១០.០០ ៧៦០៣.២០.០០

៧៨០១.១០.០០ ៧៨០១.៩១.០០ ៧៨០១.៩៩.១០ ៧៨០១.៩៩.៩០ ៧៨០៤.១១.០០ ៧៨០៤.១៩.០០ ៧៨០៤.២០.០០ ៧៩០៣.១០.០០ ៧៩០៣.៩០.០០ ៨០០១.១០.០០ ៨០០១.២០.០០ ៨០០៧.០០.២០ ៨៤១៣.១៩.១០ ៨៤១៣.២០.១០ ៨៤១៣.២០.៩០ ៨៤១៣.៥០.១០ ៨៤១៣.៧០.១០ ៨៤១៣.៧០.២២ ៨៤១៣.៧០.២៩ ៨៤១៣.៨១.១០ ៨៤១៣.៨២.១០ ៨៤៣៦.១០.១០ ៨៤៣៦.១០.២០ ៨៤៣៦.២១.១០ ៨៤៣៦.២១.២០ ៨៤៣៦.២៩.១០ ៨៤៣៦.២៩.២០ ៨៤៣៦.៨០.១១ ៨៤៣៦.៨០.១៩ ៨៤៣៦.៨០.២១ ៨៤៣៦.៨០.២៩ ៨៤៣៦.៩១.១០ ៨៤៣៦.៩១.២០ ៨៤៣៦.៩៩.១១ ៨៤៣៦.៩៩.១៩ ៨៤៣៦.៩៩.២១ ៨៤៣៦.៩៩.២៩ ៨៤៣៧.១០.១០ ៨៤៣៧.១០.២០ ៨៤៣៧.១០.៣០ ៨៤៣៧.១០.៤០ ៨៤៣៧.៨០.១០ ៨៤៣៧.៨០.២០ ៨៤៣៧.៨០.៥១ ៨៤៣៧.៨០.៦១ ៨៥១៧.១១.០០ ៨៥១៧.១២.០០ និងទីតាំងរងលេខ ៨៥១៧.១៨.០០ នៃតារាងពន្ធគយកម្ពុជាជាធរមាន ។

២. កែសម្រួលអត្រាពន្ធគយពី សាមសិបប្រាំភាគរយ (៣៥%) មកប្រាំពីរភាគរយ (៧%) សម្រាប់បណ្តាមុខទំនិញនៃទីតាំងរងលេខ ២៩០៥.១១.០០ ២៩០៥.១២.០០ ២៩០៥.១៣.០០ ២៩០៥.១៤.០០ ២៩០៥.១៦.០០ ២៩០៥.១៧.០០ ២៩០៥.១៩.០០ ២៩០៥.២២.០០ ២៩០៥.២៩.០០ ២៩០៥.៣១.០០ ២៩០៥.៣២.០០ ២៩០៥.៣៩.០០ ២៩០៥.៤១.០០ ២៩០៥.៤២.០០ ២៩០៥.៤៣.០០ ២៩០៥.៤៤.០០ ២៩០៥.៤៥.០០ ២៩០៥.៤៩.០០ ២៩០៥.៥១.០០ ២៩០៥.៥៩.០០ ២៩២១.៤៣.០០ ២៩២១.៤៦.០០ ២៩២១.៤៩.០០ ២៩២២.១៩.១០ ២៩២២.១៩.២០ ២៩២២.១៩.៩០ ២៩២២.២៩.០០ ២៩២២.៣១.០០ ២៩២២.៣៩.០០ ២៩២២.៤២.១០ ២៩២២.៤២.៩០ ២៩២២.៤៤.០០ ២៩២២.៤៩.១០ ២៩២២.៤៩.៩០ ២៩៣២.៩៩.១០ ២៩៣២.៩៩.៩០ ២៩៣៣.៣៣.០០ ២៩៣៣.៣៩.១០ ២៩៣៣.៣៩.២០ ២៩៣៣.៣៩.៣០ ២៩៣៣.៣៩.៩០ ២៩៣៣.៤១.០០ ២៩៣៣.៤៩.០០ ២៩៣៣.៥៣.០០ ២៩៣៣.៥៥.០០ ២៩៣៣.៧២.០០ ២៩៣៣.៩១.០០ ២៩៣៣.៩៩.១០ ២៩៣៣.៩៩.៩០ ២៩៣៤.៩១.០០ ២៩៣៤.៩៩.១០ ២៩៣៤.៩៩.២០ ២៩៣៤.៩៩.៣០ ២៩៣៤.៩៩.៩០ ២៩៣៩.១១.០០ ២៩៣៩.១៩.០០ ២៩៣៩.២០.០០ ២៩៣៩.៤២.០០ ២៩៣៩.៤៣.០០ ២៩៣៩.៤៩.០០ ២៩៣៩.៥១.០០ ២៩៣៩.៥៩.០០

២៩៣៩.៦៩.០០ ២៩៣៩.៩១.១០ ២៩៣៩.៩១.៩០ ២៩៣៩.៩៩.១០ និងទីតាំងរងលេខ ២៩៣៩.៩៩.៩០ នៃតារាងពន្ធគយកម្ពុជាជាធរមាន ។

**ប្រការ ២.-**

ត្រូវបានកំណត់ ពន្ធគយជាបន្ទុករបស់រដ្ឋ ចំពោះមុខទំនិញនាំចូលជាពូជដំណាំ ពូជសត្វគ្រប់ប្រភេទ ដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ហើយដោយហេតុផលបច្ចេកទេសមិនអាចបំបែក និងបន្ថយអត្រាពន្ធគយមកសូន្យភាគរយបាន ។

**ប្រការ ៣.-**

ត្រូវបានកំណត់អាករលើតម្លៃបន្ថែមជាបន្ទុករបស់រដ្ឋ ចំពោះមុខទំនិញនាំចូលដូចខាងក្រោម ៖

- ពូជដំណាំ និងពូជសត្វគ្រប់ប្រភេទដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច

- មុខទំនិញទាំងអស់ដែលស្ថិតក្នុងជំពូកទី ២៣ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដែលរួមមាន ចំណីសត្វ និងវត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វដែលជាសំណល់នៃឧស្សាហកម្មម្ហូបអាហារ

- មុខទំនិញដែលស្ថិតក្នុងទីតាំងរងទាំងអស់នៃទីតាំង ៣៨.០៨ នៃតារាងពន្ធគយកម្ពុជាជាធរមាន

- ម៉ាស៊ីនបូមទឹកនៃទីតាំងរងលេខ ៨៤១៣.១៩.១០ ៨៤១៣.១៩.២០ ៨៤១៣.២០.១០ ៨៤១៣.២០.៩០ ៨៤១៣.៥០.១០ ៨៤១៣.៥០.២០ ៨៤១៣.៦០.២០ ៨៤១៣.៧០.១០ ៨៤១៣.៧០.២២ ៨៤១៣.៧០.២៩ ៨៤១៣.៧០.៣០ ៨៤១៣.៨១.១០ ៨៤១៣.៨១.២០ ៨៤១៣.៨២.១០ និងទីតាំងរងលេខ ៨៤១៣.៨២.២០ នៃតារាងពន្ធគយកម្ពុជាជាធរមាន

- ត្រាក់ទ័រកសិកម្មនៃទីតាំងរងលេខ ៨៧០១.៩០.១១ និងទីតាំងរងលេខ ៨៧០១.៩០.១៩ នៃតារាងពន្ធគយកម្ពុជាជាធរមាន

- មុខទំនិញជាសម្ភារៈនិងម៉ាស៊ីនកសិកម្មផ្សេងទៀត ដែលទទួលបានការអនុគ្រោះរួចហើយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកន្លងមក ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៥
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ